**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

## លទ្ធផលនៃទស្សនកិច្ចការងារផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសជប៉ុន ពីថ្ងៃទី ០៦ ដល់ ០៩ ខែ សីហា ឆ្នាំ ២០១៧

តបតាមការអញ្ជើញរបស់រដ្ឋាភិបាលជប៉ុន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**កម្ពុជា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញបំពេញទស្សនកិច្ចការងារផ្លូវការនៅប្រទេសជប៉ុន ពីថ្ងៃទី០៦ដល់ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៧ ដើម្បីពង្រឹង និងពង្រីកបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពប្រពៃណីដ៏ជិតស្និទ្ធ និង កិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ ។ ទស្សកិច្ចរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**នៅជប៉ុនលើកនេះមានអត្ថន័យសំខាន់ពិសេស ដោយបានប្រព្រឹត្តទៅក្នុងឱកាសខួប៦០ឆ្នាំនៃទស្សនកិច្ចរបស់ឯកឧត្តមអតីតៈនាយករដ្ឋមន្ត្រីជប៉ុន Nobusuke Kishi នៅកម្ពុជាកាលពីឆ្នាំ១៩៥៧ ដែលជាកិច្ចចាប់ផ្តើមនៃការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំកំពូលរវាងប្រទេសទាំងពីរ និង ខួប២៥ឆ្នាំនៃការចូលរួមរបស់កម្លាំងជប៉ុនក្នុងការថែរក្សាសន្តិភាពលើកដំបូងនៅប្រទេសកម្ពុជា ក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ។ ក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានចូលគាល់ព្រះអង្គម្ចាស់រាជទាយាទ **ណារ៉ូ ហ៊ីតូ** និង បានជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម **ស៊ីនហ្សូ អាបេ** នាយករដ្ឋមន្ត្រីជប៉ុនក្នុងបរិយាកាសដ៏រីករាយស្និទស្នាល។

ស្តីអំពីទំនាក់ទំនងទ្វេភាគី **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងឯកឧត្តម **ស៊ីនហ្សូ អាបេ** បានសម្តែងការពេញចិត្តចំពោះមិត្តភាព និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងកម្ពុជា និងជប៉ុនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងអន្តរជាតិដែលមានភាពកាន់តែប្រសើរឡើង និងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណដល់រដ្ឋាភិបាល និង ប្រជាជនជប៉ុនដែលបានរួមចំណែកដ៏ថ្លៃថ្លាដល់ដំណើរការស្វែងរកសន្តិភាព និងរក្សាសន្តិភាពនៅកម្ពុជា និង បានផ្តល់ជំនួយជាច្រើនសម្រាប់ការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកម្ពុជា និងប្រជាធិបតេយ្យ។

ឯកឧត្តមនាយករដ្ឋមន្ត្រី **ស៊ីនហ្សូ អាបេ** បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៃប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងការចូលរួមចំណែកដ៏ថ្លៃថ្លារបស់កម្ពុជាក្នុងប្រតិបត្តិការថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ព្រមទាំងបញ្ជាក់ពីការបន្តជួយឧបត្ថម្ភដល់កងកម្លាំងរក្សាសន្តិភាពរបស់កម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារហូតដល់បញ្ចប់ដំណើការកាត់ក្តី។ ឯកឧត្តម **ស៊ីនហ្សូ អាបេ** ក៏បានសម្តែងក្តីរីករាយដោយ



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ឃើញថាជំនួយរបស់ជប៉ុនបានរួមចំណែកធ្វើឲ្យការបោះ ឆ្នោតឃុំសង្កាត់នៅកម្ពុជាកាលពីខែមិថុនាឆ្នាំ ២០១៧ បានប្រព្រឹត្តទៅដោយរលូនជោគជ័យ និងបានសន្យាថានឹងបន្តជួយដល់ការបោះឆ្នោតជាសាកលក្នុងឆ្នាំ២០១៨ទៀត។ ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន ក៏បានបញ្ជាក់ដែរថា ជប៉ុននឹងផ្តល់ការឧបត្ថម្ភគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា ដើម្បីសម្រេចគោលដៅក្លាយជាប្រទេសដែលមានចំណូលមធ្យមកំរិតខ្ពស់នៅឆ្នាំ២០៣០ ដោយបន្តផ្តល់ហិរញ្ញប្បទានឥតសំណង ឥណទានសម្បទាន និងការផ្ទេរបច្ចេកវិទ្យាឲ្យកម្ពុជា។

តបនឹងសំណើរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ឯកឧត្តម **ស៊ីនហ្សូ អាបេ** បានឯកភាពជម្រុញការអនុវត្តគម្រោងអាទិភាពមួយចំនួនដូចជា គម្រោងអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូន និងចរាចរក្នុងក្រុង គម្រោងធ្វើឲ្យប្រសើរប្រព័ន្ធភ័ស្តុភារកម្មនៅកម្ពុជា និងការអភិវឌ្ឍន៍ធនធានមនុស្សដើម្បីបម្រើវិស័យឧស្សាហកម្ម។ ជប៉ុននឹងសិក្សាគម្រោងបង្កើតរថភ្លើងធុនស្រាលស្វ័យប្រវត្តិលើអាកាសនៅរាជ-ធានីភ្នំពេញដែលនឹងជួយកាត់បន្ថយការកកស្ទះចរាចរ និងគ្រោះថ្នាក់ចរាចរ ហើយព្រមទាំងជួយទាក់ទាញភ្ញៀវទេសចរមកកម្ពុជាផងដែរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន** ក៏បានឯកភាពគ្នាខិតខំជំរុញការផ្លាស់ប្តូរពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការក្នុងវិស័យកសិ-ឧស្សាហកម្ម លើកទឹកចិត្តឲ្យវិនិយោគិន និង ទេសចរជប៉ុនមកកម្ពុជាឲ្យកាន់តែច្រើនថែមទៀត។ ជាមួយគ្នានេះ**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានស្វាគមន៍គម្រោងបើកស្ថានអគ្គកុងស៊ុលជប៉ុននៅខេត្តសៀមរាប។

ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុន ដែលបានជួយចូលរួមរៀបចំឯកសារ និងគាំទ្រការដាក់បញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក។ តបនឹងសំណើរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ឯកឧត្តម **ស៊ីនហ្សូ អាបេ** នឹងពិភាក្សាជាមួយប្រទេសបារាំងដែលជាសហប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់ប្រាសាទអង្គរវត្ត (ICC-Angkor) និងអង្គការយូណេស្កូ (UNESCO) ដើម្បីពិនិត្យលទ្ធភាពពង្រីកដែនសមត្ថកិច្ច ICC-Angkor គ្របដណ្តប់លើប្រាសាទសំបូរព្រៃគុកផងដែរ ហើយឆ្លៀតក្នុងឱកាសនោះឯកឧត្តម បានថ្លែងអំណរគុណកម្ពុជាដែលគាំទ្រទីក្រុងអូសាកាធ្វើជាម្ចាស់ផ្ទះពិព័រណ៍ពិភពលោកឆ្នាំ ២០២៥ និងគាំទ្រជប៉ុនជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការយូណេស្កូសម្រាប់អាណត្តិឆ្នាំ ២០១៧-២០១៩ ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានបញ្ជាក់ជាថ្មីពីការគាំទ្រចំពោះគោលនយោបាយជប៉ុន«**ចូលរួមចំណែកយ៉ាងសកម្មដើម្បីសន្តិភាព**» និង ការចូលរួមរបស់ជប៉ុនក្នុងប្រតិបត្តិការថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ព្រមទាំងបានសម្តែងការស្វាគមន៍ និងគាំទ្រចំពោះ «**យុទ្ធសាស្ត្រតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហរ**» ដែលផ្តួចផ្តើមឡើងដោយជប៉ុន ដើម្បីសន្តិភាព ស្ថិរភាព ការអភិវឌ្ឍ និងវិបុលភាពរួមនៅក្នុងតំបន់ និងលើសកលលោក។ ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពគ្នាពង្រឹងថែមទៀតនូវកិច្ចសហការរវាងប្រទេសទាំងពីរក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ និងលើ វេទិកាអន្តរជាតិ ហើយបានផ្លាស់ប្តូរយោបល់គ្នាផងដែរអំពីបញ្ហាតំបន់ ដែលរួមមានស្ថានការណ៍នៅឧបទ្វីបកូរ៉េ និងបញ្ហាសមុទ្រចិនខាងត្បូង។

ក្នុងឱកាសជំនួបទ្វេភាគីនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្នើអញ្ជើញឯកឧត្តម **ស៊ីនហ្សូ អាបេ** ពិនិត្យលទ្ធភាពមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជាក្នុងឆ្នាំ២០១៧ តាមពេលវេលាសមស្រប ដើម្បីពង្រឹង និងពង្រីកបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាដៃគូយុទ្ធសាស្ត្រ រវាងកម្ពុជា និងជប៉ុន ជាពិសេសក្នុងឱកាសប្រារព្ធខួប៦០ឆ្នាំ នៃការចាប់ផ្តើមផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ដឹកនាំកំពូលរបស់ប្រទេសទាំងពីរ និង ខួប២៥ឆ្នាំនៃការចូលរួមរបស់កម្លាំងជប៉ុនក្នុងការថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិលើកដំបូងនៅប្រទេសកម្ពុជា។ បន្ទាប់ពីជំនួបទ្វេភាគី **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង ឯកឧត្តម **ស៊ីនហ្សូ អាបេ** បានអញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារស្តីពីការផ្តល់ជំនួយរបស់ជប៉ុនដល់កម្ពុជា សរុបជាទឹកប្រាក់ប្រមាណជា **២៤០ លានដុល្លារអាមេរិក** ដែលក្នុងនោះរួមមាន៖

(១) ហិរញ្ញប្បទានឥតសំណង**៣.៩៤៨**លានយ៉េន(ប្រមាណ**៣៥**លានដុល្លាអាមេរិក) សម្រាប់អនុវត្ត **គម្រោងធ្វើឲ្យប្រសើរឡើងវិញការការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញដំណាក់-កាលទី៤**។

(២) ការផ្តល់ឥណទានសប្បទាន **២៣.៥០២**លាន យ៉េន (ប្រមាណ២០៩លានដុល្លាអាមេរិក) សម្រាប់អនុវត្តគម្រោង**អភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ** ។

ឆ្លៀតក្នុងឱកាសដំណើរទស្សនកិច្ចការងារផ្លូវការនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានទទួលការចូលជួបសម្តែងការគួរសមដាច់ដោយឡែកគ្នាពីសំណាក់ប្រធានរបស់ (១)សមាគមមិត្តភាពសភាជប៉ុន-កម្ពុជា សមាគមមិត្តភាពសភាជប៉ុន-មេគង្គ មូលនិធិជប៉ុន សមាគមជប៉ុន-កម្ពុជា អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន និងក្រុមហ៊ុនជប៉ុនចំនួន៤។ **សម្តេចតេជោនាយករដ្ឋន្ត្រី** ក៏បានចូលរួមថ្លែងសុន្ទរកថាគន្លឹះក្នុងសិក្ខាសាលាក្រោមប្រធានបទ **«ការស្វែងយល់អំពីកម្ពុជាពេលបច្ចុប្បន្ន»** ដែលរៀបចំដោយសមាគមជប៉ុន-កម្ពុជា និងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ព្រមទាំងស្ថាប័នពាក់ព័ន្ធ ហើយនិងបានអញ្ជើញធ្វើទស្សនកិច្ចនៅរោងចក្រកែច្នៃកាកសំណល់ និងធ្វើដំណើរសាកល្បងតាមរថភ្លើងធុនស្រាលស្វ័យប្រវត្តិ។

ក្នុងពេលអញ្ជើញទៅដល់ទីក្រុងតូក្យូភ្លាម **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជាដែលកំពុងសិក្សានៅជប៉ុនចំនួនជាង១២០ នាក់ ក្នុងបរិយាកាសដ៏រីករាយក្រៃលែង ដោយ**សម្តេចតេជោ**បានផ្តាំផ្ញើឲ្យនិស្សិតកម្ពុជា ខិតខំរៀនសូត្រ និងយកចំណេះដឹង និងជំនាញដែលទទួលបានពីការសិក្សានៅជប៉ុន ទៅចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧